# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៨៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើត គណៈកម្មាធិការជាតិ លើកកម្ពស់ សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ

* * *

## រាជរដ្ឋាភិបាល

-បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខនស/រកម/០៨៩៥/០៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសារពត៌មាន

-បានឃើញព្រះរាជក្រមលេខនស/រកម/០១០៥/០០២ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី

-បានឃើញអនុក្រឹត្យលេខ១៣អនក្រ.បក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី

-បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការគ្រប់គ្រង ត្រួតពិនិត្យសិល្បៈភាពយន្ត និងវីដេអូ

- យោងតាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី

# សម្រេច

**មាត្រា ១.-**

អនុក្រឹត្យនេះ កំណត់ការបង្កើតគណៈកម្មាធិការជាតិ ដើម្បីលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ហៅកាត់ថា **គ.ជ.ស.ស.ខ** ក្នុងគោលបំណងថែរក្សា ការពារវប្បធម៌ជាតិ ធានាដល់ការគោរព សីលធម៌សង្គម និងសុភមង្គលនៅក្នុងគ្រួសារ ដោយលើកកម្ពស់ស្ថានភាព តួនាទី សុខុមាលភាពស្ត្រីខ្មែរ ។

**មាត្រា ២.-**

**គ.ជ.ស.ស.ខ** មានសមាសភាពដូចតទៅ ÷

| | |
|---|---|
| ១. លោកជំទាវ ភរិយាសម្តេចនាយករដ្ឋមន្ត្រី | ប្រធានកិត្តិយស |
| ២. រដ្ឋមន្ត្រីក្រសួងកិច្ចការនារី | ប្រធាន |
| ៣. រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី | ១រូប អនុប្រធានអចិន្ត្រៃយ៍ |
| ៤. រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ១រូប អនុប្រធាន |
| ៥. រដ្ឋលេខាធិការ ក្រសួងព័ត៌មាន | ១រូប អនុប្រធាន |
| ៦. រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | ១រូប អនុប្រធាន |
| ៧. រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១រូប សមាជិក |
| ៨. អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ១រូប សមាជិក |
| ៩. អនុរដ្ឋលេខាធិការក្រសួងការពារជាតិ | ១រូប សមាជិក |
| ១០. អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | ១រូប សមាជិក |
| ១១. អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១រូប សមាជិក |
| ១២. អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ១រូប សមាជិក |
| ១៣. អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ១រូប សមាជិក |
| ១៤. អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ១រូប សមាជិក |
| ១៥. អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | ១រូប សមាជិក |
| ១៦.អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី | ១រូប សមាជិក |
| ១៧.អនុរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា | ១រូប សមាជិក |
| ១៨.តំណាងអគ្គស្នងការនគរបាលជាតិ | ១រូប សមាជិក |
| ១៩.តំណាងកងរាជអាវុធហត្ថលើផ្ទៃប្រទេស | ១រូប សមាជិក |

២០.អភិបាលរាជធានីភ្នំពេញ សមាជិក

ការតែងតាំងសមាសភាព **គ.ជ.ស.ស.ខ** ខាងលើនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ។

**មាត្រា ៣.-**

**គ.ជ.ស.ស.ខ** មានភារកិច្ចដូចតទៅ ÷

១- តាមដានណែនាំ និងជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាពនូវអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការគ្រប់គ្រង ត្រួតពិនិត្យសិល្បៈភាពយន្ត និង វីដេអូ សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ១០សសរ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០១ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងបង្ក្រាបបទល្មើស ភាពយន្ត និង វីដេអូ និង សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ១៤សសរ ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងបង្ក្រាបការធ្វើអាជីវកម្ម បញ្ចាំង និង លក់កាសែ្សតវីដេអូអាសអាភាស ។

២- សហការជាមួយស្ថាប័នមានសមត្ថកិច្ចពាក់ពន្ធ័ ដើម្បីទប់ស្កាត់ឱ្យទាន់ពេលវេលានូវរាល់ការផ្សព្វផ្សាយ រូបភាពអាសអាភាស តាមគ្រប់មធ្យោបាយ ដែលធ្វើឱ្យប៉ះពាល់ដល់សីលធម៌សង្គម និងតម្លៃស្ត្រីខ្មែរ ។

៣- ផ្តួចផ្តើមបង្កើតយុទ្ធសាស្ត្រ សម្រាប់អនុវត្តប្រឆាំងវប្បធម៌ហិង្សាក្នុងសង្គម និងសង្គមអសីលធម៌ ដែលនាំឱ្យប៉ះពាល់ដល់សុភមង្គលក្នុងគ្រួសារ ដោយជំរុញឱ្យស្ត្រីធ្លាក់ក្នុងភាពងាយរងគ្រោះ ។

៤- តាមដានត្រួតពិនិត្យ និងទប់ស្កាត់ការហូរចូល នូវវប្បធម៌អសកម្ម វប្បធម៌ហិង្សាពីបរទេស ដែលនិយមយកស្ត្រីខ្មែរជាទំនិញ ជាឧបករណ៍កំសាន្ត ជាឧបករណ៍ផ្សព្វផ្សាយពាណិជ្ជកម្ម នាំឱ្យប៉ះពាល់ដល់ភាពថ្លៃថ្នូរ តម្លៃ និងកិត្តិយសរបស់ស្ត្រីខ្មែរ ។

៥- សហការជាមួយស្ថាប័នរដ្ឋ អង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល និងផ្នែកឯកជន ដើម្បីអប់រំផ្សព្វផ្សាយតាមគ្រប់រូបភាព ដល់មន្ត្រីរាជការកងកម្លាំងប្រដាប់អាវុធ ប្រជាពលរដ្ឋ ពីផលប៉ះពាល់អវិជ្ជមាន នៃការទស្សនា និងការផ្សព្វផ្សាយរូបភាពអាសអាភាស ។

៦- បង្កើតកម្មវិធី យុទ្ធនាការផ្សព្វផ្សាយអប់រំ ដល់យុវវ័យ កុមារា កុមារី ប្រជាពលរដ្ឋ ឱ្យចេះស្រឡាញ់ ការពារវប្បធម៌ប្រពៃណីខ្មែរ និងតម្លៃសីលធម៌សង្គម ។

៧- រៀបចំកិច្ចប្រជុំប្រចាំត្រីមាស រវាងស្ថាប័នរដ្ឋ និងវិស័យឯកជន ហើយធ្វើរបាយការណ៍លើកអនុសាសន៍ជូនរាជរដ្ឋាភិបាល ។

៨- រៀបចំសន្និបាតប្រចាំឆ្នាំក្រោមអធិបតីភាព លោកជំទាវភរិយាសម្តេចនាយករដ្ឋមន្ត្រី ប្រធានកិត្តិយស **គ.ជ.ស.ស.ខ** ដើម្បីបូកសរុបលទ្ធផលកន្លងមក និង លើកផែនការអនុវត្តបន្ត ។

**មាត្រា ៤.-**

សមាជិក **គ.ជ.ស.ស.ខ** ត្រូវចូលរួមប្រជុំតាមការអញ្ជើញ របស់ប្រធានគណៈកម្មាធិការជាតិ ។ ក្នុងករណីចាំបាច់ **គ.ជ.ស.ស.ខ** អាចអញ្ជើញតំណាងស្ថាប័នជាតិផ្សេងទៀត ស្ថាប័នឯកជន និង តំណាងអង្គការជាតិ អន្តរជាតិពាក់ព័ន្ធចូលរួមប្រជុំ ។

**មាត្រា ៥.-**

**គ.ជ.ស.ស.ខ** ត្រូវបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍ប្រចាំនៅក្រសួងកិច្ចការនារី ដោយប្រើប្រាស់មន្ត្រីមានក្របខ័ណ្ឌស្រាប់ ដើម្បីជាជំនួយការក្នុងកិច្ចសហការសម្របសម្រួលការងារដែលពាក់ព័ន្ធនឹងបញ្ហាលើកកម្ពស់សីលធម៌ សង្គម តម្លៃស្ត្រី និង គ្រួសារខ្មែរ ។ តួនាទីភារកិច្ចរបស់លេខាធិការដ្ឋានអចិន្ត្រៃយ៍ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ **គ.ជ.ស.ស.ខ** ។ គណៈកម្មាធិការជាតិនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងកិច្ចការនារី ។

**មាត្រា ៦.-**

**គ.ជ.ស.ស.ខ** អាចបង្កើតអនុគណៈកម្មាធិការជំនាញអន្តរក្រសួងមួយចំនួន តាមការចាំបាច់ ជាជំនួយការ ក្នុងកិច្ចសហការសម្របសម្រួលភារកិច្ចរបស់ខ្លួន ដូចមានចែងក្នុងមាត្រា៣ នៃអនុក្រឹត្យនេះ ។ ការតែងតាំងសមាសភាព តួនាទី និង ភារកិច្ចរបស់អនុគណៈកម្មាធិការជំនាញអន្តរក្រសួងនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ។

**មាត្រា ៧.-**

**គ.ជ.ស.ស.ខ** ត្រូវបង្កើតគណៈកម្មការចម្រុះថ្នាក់ខេត្តក្រុង ជាអង្គភាពប្រតិបត្តិការផ្ទាល់នៅមូលដ្ឋាន ក្នុងកិច្ចសហការសម្របសម្រួលភារកិច្ចរបស់ខ្លួន ដូចមានចែងក្នុងមាត្រា៣ នៃអនុក្រឹត្យនេះ ។ គណៈកម្មការចម្រុះថ្នាក់ខេត្តក្រុង ដឹកនាំដោយអភិបាល ឬអភិបាលរងខេត្តក្រុង និងសមាជិកមកពីមន្ទីរពាក់ព័ន្ធ ដូចក្នុងមាត្រា២ នៃអនុក្រឹត្យនេះ លើកលែងតែស្ថាប័នណា ដែលមិនមានអង្គភាពចំណុះនៅតាមបណ្តាខេត្តក្រុង ។

ការកំណត់សមាសភាព តួនាទី និងភារកិច្ចរបស់គណៈកម្មការចម្រុះថ្នាក់ខេត្តក្រុង ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ជ.ស.ស.ខ** ។ គណៈកម្មការចម្រុះថ្នាក់ខេត្តក្រុង មានសិទ្ធិប្រើប្រាស់ត្រារបស់សាលាខេត្តក្រុង ។

**មាត្រា ៨.-**

**គ.ជ.ស.ស.ខ** មានថវិកាផ្ទាល់ខ្លួន ដែលជាថវិកាពិសេសរបស់រាជរដ្ឋាភិបាល ឬ ថវិកាជំនួយឧបត្ថម្ភពីអង្គការអន្តរជាតិ ប្រទេសផ្តល់ជំនួយ និងសប្បុរសជនជាតិ ឬ អន្តរជាតិ ។

**មាត្រា ៩.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ននិងអង្គភាពពាក់ព័ន្ធ ដូចចែងក្នុងមាត្រា២ខាងលើ មានភារកិច្ចអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៦

ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចនាយករដ្ឋមន្ត្រី សូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងកិច្ចការនារី**

**អ៊ឹង កន្ថាផាវី**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
-គ្រប់សាលាខេត្តក្រុង
- រាជកិច្ច
-ដូចមាត្រា១០
-ឯកសារ-កាលប្បវត្តិ